ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៤៨
ចុះថ្ងៃទី២៩-៨-២០១១
សាលដីកា
លេខ: ២៥ ក្រ៥.ប
ចុះថ្ងៃទី៣០-៤-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី១៨-៤-២០១៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៧៤៨ ចុះថ្ងៃទី ២៩-៨-២០១១ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ របរកស៊ី កម្មកររោងចក្រ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃនៅស្នាក់នៅផ្ទះ [redacted] ទោសពីមុនគ្មាន ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន ឃុំខ្លួនកាលពីថ្ងៃទី ១៤-១០-២០០៩ ។

ជាប់ចោទពីបទ: ប្លន់ (លួចខោខូវប៊យ) ប្រព្រឹត្តនៅភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-៩-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទា ទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ពានទំងន់ទោសបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមហ៊ុនសន្តិសុខហ្គាវ៉ដា តំណាងដោយលោក [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅសង្កាត់ទួលស្វាយព្រៃ...

៧៩២

[redacted] ។

<u>ឯរឿងហេតុមានដូចតទៅ:</u>

កាលពីថ្ងៃទី ១៣-៩-២០០៨ វេលាម៉ោង ១១.៣០នាទី ឈ្មោះ [redacted] រិទ្ធី ភេទប្រុស ជាកម្មករ ផ្នែកបោកគក់ក្នុងរោងចក្រជូស៊ីងហ្គាមិន ដែលស្ថិតនៅភូមិខ្វរ សង្កាត់ព្រៃកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឈ្មោះ [redacted] រិទ្ធី ព្រមទាំងបក្ខពួកបានធ្វើសកម្មភាពលួចខោខូវប៊យពីក្នុងអគារបោកគក់ច្រកដាក់ក្នុងការ៉ុង រួចយកទៅខាងក្រៅរោងចក្រ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១២១(កប.៥) ចុះថ្ងៃទី២៨-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

- ផ្ដន្ទាទោស:

- ឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ: ប្លន់ (លួចមានគ្នា) ប្រព្រឹត្តនៅភូមិខ្វរ សង្កាត់ព្រៃកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-៩-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- សាលក្រមនេះជំនុំជំរះ នៅថ្ងៃទី២៩-៩-២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨-១០-២០១០ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៨២៥ ចុះថ្ងៃទី១៩-១១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២១(កប.៥) ចុះថ្ងៃទី២៨-១១-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្ដីសំរេចសាលក្រមទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី២១-១០-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២០-១២-២០១១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី (វត្តមាន)

- មានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ លោក [redacted] រដ្ឋា (វត្តមាន)

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

- ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកនេះ ព្រោះជាប់ទណ្ឌកម្មខ្លួនខ្ពស់ពេក ចាប់ពីពេលនេះទៅខ្លួនឈប់លួចគេទៀតហើយ ។ ខ្លួនទទួលស្គាល់អង្គហេតុនេះហើយ ម្យ៉ាងទៀតពេលលួចនោះមិនមាន ការគាស់ទម្លុះទម្លាយទេ នៅពេលអ្នកធ្វើការជាមួយគ្នានោះ គេបើកសោរឆ្លៀតឱកាសពេលគេចេញទៅហូបបាយ ខ្លួនក៏លួច

នៅម៉ោង ១២ថ្ងៃត្រង់ ឯសោរជនជាតិចិនជាអ្នកកាន់កាប់ ។ ខ្លួនធ្វើសកម្មភាពលួចខោនេះ គឺបន្លំនៅក្នុងរោងចក្រ នៅពេលកម្មករចេញទៅហូបបាយថ្ងៃត្រង់ដោយសាររោងចក្រ នៅជិតមាត់ទន្លេនៅពេលយកខោឲ្យគេអ៊ុតឆ្លៀតពេលនោះខ្លួនក៏លួចបណ្ដោះចេញ ។ ពេលនេះខ្លួនសំណូមពរ សុំបន្ធូរបន្ថយទោសដល់ខ្លួនផង ។

**តំណាងមហាអយ្យការសន្និដ្ឋានថាៈ**

តំណាងមហាអយ្យការសុំសន្និដ្ឋានសរុបពីររឿង គឺសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤៦ ចុះថ្ងៃទី ២៩-៨-២០១១ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤៨ ចុះថ្ងៃទី២៩-៨-២០១១ តាមច្បាប់ថ្មី យល់ឃើញថា ជនជាប់ចោទបានសារភាព តំណាងមហាអយ្យការសំណូមពរ សូមក្រុមប្រឹក្សាធ្វើការបូកសរុបទោសបញ្ចូលគ្នា ហើយបញ្ជាក់នូវទោសបើប្រភេទដូចគ្នា ដោយសូមឲ្យសម្រេចបញ្ចូលទោសចុះនេះជាការស្នើសុំពីតំណាងមហាអយ្យការ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានៈ**

- លោក [redacted] រដ្ឋា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថាៈ ឆ្លងកាត់ការសួរដេញដោលកូនក្ដីខ្លួនបានសារភាពអស់ហើយៗ គឺលួចដោយគ្មានអំពើហិង្សា គ្មានព្យសនកម្មធ្ងន់ធ្ងរទេ ។ ចំណែកអំពើរបស់កូនក្ដីខ្លួនជាបទលួចធម្មតាទេ ហើយក្រមថ្មីមានលក្ខណៈស្រាលចំពោះទណ្ឌកម្មរបស់កូនក្ដីខ្លួន ។ សំណូមពរ សុំឲ្យតុលាការអនុវត្តតាមច្បាប់ថ្មី ហើយការសួរដេញដោលរបស់កូនក្ដីខ្លួននេះ គឺមានបទល្មើសត្រួតគ្នា ។ សំណូមពរ សុំឲ្យតុលាការប្រកាសទោសស្របបញ្ចូលគ្នា រឿងនេះមិនមែនទោសមិនរាងចាលទេ ការប្រព្រឹត្តរបស់កូនក្ដីខ្លួន គឺដើម្បីជីវភាពតែប៉ុណ្ណោះ ។ មេត្តាសម្រាលទោស និងបន្ធូរបន្ថយទោសកូនក្ដីខ្លួនផងនូវរឿងទាំងពីរនេះ ។

- ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍យល់ឃើញថាៈ**

១- បណ្ដឹងឧទ្ធរណ៍លេខ ៨២៥ ចុះថ្ងៃទី១៩-១១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមទាំងមូល បណ្ដឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២- ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ២៥ឆ្នាំ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទៈ ប្លន់ លើមានស្ថានទោស គឺលួចខោខូវប៊យចេញពីអគារបោកគក់មួយកន្លែងដែលមានឈ្មោះ ជ័យ ជុះ ប្រាក់មិន ស្ថិតនៅភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩-៥-២០០៨ ។

៣- នៅចំពោះមុខសាលាឧទ្ធរណ៍ ជនជាប់ចោទបានឆ្លើយបញ្ជាក់ថា ការដែលខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺក្នុងគោលបំណងសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូបន្ថយទោស ព្រោះខ្លួនទទួលស្គាល់អង្គហេតុដែលកើតមានឡើងកន្លងមក នឹងមានការសោកស្តាយចំពោះកំហុសរបស់ខ្លួន ហើយខ្លួនក៏បានអនុវត្តទណ្ឌកម្មបានមួយចំនួនធំហើយ ធ្វើឲ្យខ្លួនកាន់តែយល់ច្បាស់នូវទង្វើទាំងឡាយណាដែលនាំមកភាពគ្រោះថ្នាក់ប៉ះពាល់សណ្តាប់ធ្នាប់សង្គម ការអះអាងនេះសាលាឧទ្ធរណ៍គប្បីលើកមកពិនិត្យ ពិចារណាឲ្យបានសមស្រប ម្យ៉ាងវិញទៀត បទចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ពីបទៈ ប្លន់ (លួចមានគ្នា) តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនោះ ឃើញថាមិនស្រប តាមអង្គហេតុឡើយ ដូចនេះគប្បីកែប្រែបទចោទប្រកាន់ ពីបទៈ ប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជា បទៈ លួច តាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ ។

៤- តុលាការសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ ។

៥- សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ១២១ (កប៥) ចុះថ្ងៃទី២៨-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី គួរពិចារណាជាថ្មីតាមបញ្ញត្តិមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ ដើម្បីជាប្រយោជន៍របស់ជនជាប់ចោទ ។

**ហេតុដូច្នេះ**

**ឧនិច្ឆ័យសេចក្តី:**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨២៥ ចុះថ្ងៃទី១៩-១១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ពីបទៈ ប្លន់ (លួចមានគ្នា) តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ មកជា បទៈ លួច តាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២១ (កប៥) ចុះថ្ងៃទី២៨-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទៈ ប្លន់ (លួចមានគ្នា) តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ត្រូវកែប្រែ មកជា ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ ពីបទៈ លួច តាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌវិញ ក្រៅពីនេះរក្សាទុកដដែល ។

៤- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨-៤-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០-៤-២០១៤ ។

- បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខាៈ [redacted] | ហត្ថលេខាៈ [redacted], [redacted] | ហត្ថលេខាៈ [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៥
ក្រឡាបញ្ជី

[redacted]

២៩៦